**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
* * * * * *

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
* * * * * *

# ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ទទួល ឯកឧត្តម វូ ក្វាងមិញ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា

នៅព្រឹកថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១ នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឲ្យ **ឯកឧត្តម វូ ក្វាងមិញ** (Vu Quang Minh) ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា ក្នុងឱកាសដែល**ឯកឧត្តម**បានបញ្ចប់បេសកកម្មការទូតនៅកម្ពុជា។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានអបអរសាទរចំពោះ **ឯកឧត្តមឯកអគ្គរដ្ឋទូត** ដែលបានបញ្ចប់បេសកកម្មការទូតប្រកបដោយជោគជ័យនៅកម្ពុជា ហើយទទួលបានគ្រឿងឥស្សរិយយសសហមេត្រី ថ្នាក់មហាសេរីវឌ្ឍន៍ ពីរាជរដ្ឋាភិបាលកម្ពុជា ចំពោះកិច្ចខិតខំប្រឹងប្រែង និងការចូលរួមចំណែករបស់**ឯកឧត្តម** ក្នុងការបន្តលើកកម្ពស់ និងពង្រឹងបន្ថែមទៀតនូវទំនាក់ទំនងជាអ្នកជិតខាងល្អ មិត្តភាពជាប្រពៃណី និងកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ រវាងប្រទេសទាំងពីរ ដើម្បីផលប្រយោជន៍របស់ប្រជាជនកម្ពុជា និងវៀតណាម។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ជាថ្មីម្តងទៀតបានអបអរសាទរប្រទេសវៀតណាមដែលទទួលបានជោគជ័យក្នុងការរៀបចំមហាសន្និបាតបក្សកុម្មុយនិស្តវៀតណាមលើកទី១៣ និងសម័យប្រជុំទី១១ នីតិកាលទី១៤ នៃរដ្ឋសភាវៀតណាម ហើយនិងការបំពេញតួនាទី និងអាណត្តិរបស់ខ្លួនប្រកបដោយជោគជ័យ ក្នុងនាមជាប្រធានអាស៊ាន និងក្នុងឋានៈជាសមាជិកមិនអចិន្ត្រៃយ៍ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។

ជាកិច្ចឆ្លើយតប **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានថ្លែងអំណរគុណជាពិសេសជូនចំពោះ**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ដែលទទួលសវនាការរបស់ឯកឧត្តមនៅក្នុងពេលវេលានេះ និងកិច្ចសហប្រតិបត្តិការដ៏ល្អរបស់ថ្នាក់ដឹកនាំ និងមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលបានរួមចំណែកធ្វើឱ្យបេសកកម្មការទូតរបស់ឯកឧត្តមនៅកម្ពុជា ទទួលបានជោគជ័យ ។

ភាគីទាំងពីរ បានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងដ៏ល្អ និងការរក្សាបាននូវទំនាក់ទំនងជិតស្និទ្ធ រវាងថ្នាក់ដឹកនាំជាន់ខ្ពស់នៃប្រទេសទាំងពីរ តាមរយៈការជួបប្រជុំផ្លាស់ប្តូរយោបល់តាមប្រព័ន្ធវីដេអូ និងទូរស័ព្ទ ដែលបានជួយពូនជ្រុំ និងរួមចំណែកធ្វើឱ្យទំនាក់ទំនងទ្វេភាគី និងកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្កាលើគ្រប់វិស័យរវាងប្រទេសទាំងពីរ កាន់តែជិតស្និទ្ធ និងល្អប្រសើរឡើងថែមទៀត។

ក្នុងឱកាសនៃសវនាការនេះ **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានគូសបញ្ជាក់ថា កម្ពុជា គឺជាមិត្តដ៏ពិសេស និងជាដៃគូដ៏មានសារៈសំខាន់របស់វៀតណាម។ ប្រទេសយើងទាំងពីរកាន់តែមានការយល់ពីគ្នាឡើង និងគោរពផលប្រយោជន៍គ្នាទៅវិញទៅមក។ **ឯកឧត្តម** ក៏បានកោតសរសើរអំពីសេរីភាពដ៏ទូលំទូលាយនៃការធ្វើទំនាក់ទំនងតាមប្រព័ន្ធបណ្តាញសង្គមនៅកម្ពុជា ដែលអនុញ្ញាតឱ្យ**ឯកឧត្តម** អាចធ្វើការជាមួយថ្នាក់ដឹកនាំកម្ពុជា និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ប្រកបដោយប្រសិទ្ធភាព និងឆាប់រហ័ស នៅក្នុងកាលៈទេសៈបច្ចុប្បន្ននេះ។

នាចុងបញ្ចប់នៃជំនួប **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានជូនពរឯកឧត្តម **វូ ក្វាងមិញ** ទទួលបានជោគជ័យជាបន្តទៀតនៅក្នុងភារកិច្ចថ្មីនាពេលអនាគតរបស់ឯកឧត្តម ៕

------------